## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកសិកម្ម**
**នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម**

## គម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរៈបរិស្ថាន

**Climate-Friendly Agribusiness Value Chains Sector Project (CFAVC)**
**ADB Loan No. 3661-CAM (COL), 8346-CAM (EF) and Grant No. 0579 (EF)**

# ឯកសារមេរៀនបណ្តុះបណ្តាល
# ស្តីពី
# គំរូរបាយការណ៍ប្រចាំឆ្នាំ
# សម្រាប់សហគមន៍កសិកម្ម

រៀបចំដោយ៖ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម (DACP)

**ខែ កញ្ញា ឆ្នាំ២០២០**

**គំរូរបាយការណ៍ប្រចាំឆ្នាំ**

បោះពុម្ពផ្សាយ៖ ខែកុម្ភៈ ឆ្នាំ២០១៦

បោះពុម្ពដោយ៖ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម (MAFF)

គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

អស័យដ្ឋាន៖ # ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់ ៣ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា

ទូរស័ព្ទ៖ (០២៣) ៨៨៣ ៤២៧    ទូរសារ៖ (០២៣) ៨៨៣ ៤២៧

© គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

# មាតិកា


1. **សកម្មភាពសំខាន់ៗរបស់សហគមន៍កសិកម្ម** ..... 1

2. **ការងាររដ្ឋបាល** ..... 2

2.1 ការប្រជុំ ..... 2

3. **រចនាសម្ព័ន្ធគ្រប់គ្រងរបស់សហគមន៍កសិកម្ម** ..... 3

3.1 ព័ត៌មានសមាជិកសហគមន៍កសិកម្ម ..... 3

3.2 ព័ត៌មានថ្នាក់ដឹកនាំ (ក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ) ..... 4

3.3 បុគ្គលិកជួលពីខាងក្រៅ ..... 4

3.4 ព័ត៌មានភាគហ៊ុន ..... 4

4. **សកម្មភាពអប់រំរបស់សហគមន៍កសិកម្ម** ..... 5

4.1 ក្រុមប្រឹក្សាភិបាល ..... 5

4.2 គណៈកម្មាធិការត្រួតពិនិត្យ ..... 5

4.3 សមាជិកសហគមន៍កសិកម្ម ..... 5

5. **ទ្រព្យសម្បត្តិសហគមន៍កសិកម្ម** ..... 6

5.1 ទ្រព្យសម្បត្តិ ..... 6

6. **មុខរបរ ឬ មុខជំនួញរបស់សហគមន៍កសិកម្ម** ..... 6

6.1 មុខរបរឥណទាន ..... 6

6.2 មុខរបរផ្គត់ផ្គង់ ..... 8

6.3 មុខរបរទីផ្សារ ..... 9

6.4 មុខរបរសេវាប្រើប្រាស់រួមគ្នា ..... 11

6.5 មុខរបរផ្សេងៗ ..... 11

7. **របាយការណ៍លទ្ធផល " ចំណេញ/(ខាត)"** ..... 12

8. **ការបែងចែកប្រាក់ចំណេញ** ..... 14

9. **តារាងតុល្យការ** ..... 15

10. **របាយការណ៍គណៈកម្មាធិការត្រួតពិនិត្យ** ..... 17

11. **កំណត់ហេតុមហាសន្និបាតប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម** ..... 19

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## សហគមន៍កសិកម្មអង្គររុងរឿង

## របាយការណ៍ប្រចាំឆ្នាំ2015

### 1. សកម្មភាពសំខាន់ៗរបស់សហគមន៍កសិកម្ម

សហគមន៍កសិកម្មអង្គររុងរឿង បានបង្កើតនៅថ្ងៃទី23 ខែធ្នូ ឆ្នាំ2008 ដែលមានអាសយដ្ឋានស្ថិតនៅភូមិ "ក" ឃុំ "ខ" ស្រុក "គ" ខេត្ត "ឃ" ។

របាយការណ៍ប្រចាំឆ្នាំនេះ បានឆ្លុះបញ្ចាំងពីការគ្រប់គ្រងនិងការប្រកបមុខរបររយៈពេលពេញមួយឆ្នាំរបស់សហគមន៍កសិកម្មដោយគិតចាប់ពីថ្ងៃទី 01 ខែមករា ឆ្នាំ2015 ដល់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2015។ នៅចុងឆ្នាំ2015នេះ សហគមន៍កសិកម្មអង្គររុងរឿងមានសមាជិកសរុបចំនួន120នាក់ ដែលក្នុងនោះមានស្រីចំនួន75នាក់ មានភាគហ៊ុនសរុបចំនួន1000 ហ៊ុន។ សហគមន៍កសិកម្ម អង្គររុងរឿង បានរកប្រាក់ចំណូលដុលសរុបពីមុខរបរទាំងអស់ ចំនួន 149,600,000 រៀល ពីមុខរបរទាំងអស់ចំនួន 4 ដូចខាងក្រោមគឺៈ

(ក)មុខរបរឥណទាន (ប្រាក់បញ្ញើសន្សំ ប្រាក់ផ្ញើធនាគារ ប្រាក់ឱ្យគេខ្ចី) ទទួលបានការប្រាក់សរុប ចំនួន 19,300,000 រៀល ពីការប្រាក់នៃប្រាក់ឱ្យសមាជិកនិងមិនមែនសមាជិកខ្ចី និងការប្រាក់នៃប្រាក់ផ្ញើរធនាគារ នៅក្នុងឆ្នាំ2015 ។

(ខ)មុខរបរផ្គត់ផ្គង់ (ទិញពីខាងក្រៅយកមកផ្គត់ផ្គង់ជូនសមាជិកសហគមន៍កសិកម្ម និងអ្នកខាងក្រៅដូចជាផ្គត់ផ្គង់ជីកសិកម្ម ជាដើម) បានរកប្រាក់ចំណូលដុលសរុប (មិនទាន់ដកថ្លៃដើម និងចំណាយផ្សេងៗ) ចំនួន 48,000,000 រៀល នៅក្នុងឆ្នាំ2015 ។

(គ)មុខរបរទីផ្សារ (ប្រមូលផលិតផលកសិកម្មដូចជាស្រូវ អង្ករ ពីសមាជិកយកទៅលក់នៅទីផ្សារ) បានរកប្រាក់ចំណូលដុលសរុប (មិនទាន់ដកថ្លៃដើម និងចំណាយផ្សេងៗ) ចំនួន 72,300,000 រៀល នៅក្នុងឆ្នាំ2015 ។

(ឃ)មុខរបរផ្តល់សេវាប្រើប្រាស់រួមគ្នា (ការជួលត្រាក់ទ័រ) បានរកប្រាក់ចំណូលដុលសរុប (មិនទាន់ដកចំណាយផ្សេងៗ) ចំនួន 10,000,000 រៀល ។

(ង)មុខរបរផ្សេងៗបានរកប្រាក់ចំណូលដុលសរុប (មិនទាន់ដកចំណាយផ្សេងៗ) ចំនួន………………………… រៀល នៅក្នុងឆ្នាំ2015។

# 2. ការខារេដ្ឋបាល

## 2.1 ការប្រជុំ

### 2.1.1 ប្រជុំមហាសន្និបាតប្រចាំឆ្នាំ

(នៅថ្ងៃទី20 ខែមីនា ឆ្នាំ2015 មានការរៀបចំកិច្ចប្រជុំមហាសន្និបាតប្រចាំឆ្នាំមួយ ដែលរាយការណ៍ពីលទ្ធផលនៃរបាយការណ៍ជំនួញ របាយការណ៍ហិរញ្ញវត្ថុនៅក្នុងឆ្នាំ2014 និងផែនការជំនួញសម្រាប់ឆ្នាំ2015)

| ប្រជុំមហាសន្និបាតប្រចាំឆ្នាំ2014 | ថ្ងៃទី20 ខែមីនា ឆ្នាំ2015 | | |
|---|---|---|---|
| | របៀបវារៈសំខាន់ៗ | ចំនួនសមាជិកសហគមន៍កសិកម្មបានចូលរួមសរុប (នាក់) | ចំនួនសមាជិកសហគមន៍កសិកម្មសរុប (នាក់) |
| | 1. របាយការណ៍ជំនួញសម្រាប់ឆ្នាំ2014<br>2. របាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ2014<br>3. ប្រាក់បញ្ញើសន្សំរបស់សមាជិកសម្រាប់ឆ្នាំ2014<br>4. ផែនការជំនួញសម្រាប់ឆ្នាំ2015 | 100 | 120 |

### 2.1.2 ប្រជុំមហាសន្និបាតវិសាមញ្ញ

(ប្រជុំមហាសន្និបាតវិសាមញ្ញ គឺជាការកោះប្រជុំសមាជិកទាំងអស់ដើម្បីដោះស្រាយបញ្ហាភ្លាមៗ)

| ប្រជុំមហាសន្និបាតវិសាមញ្ញ | របៀបវារៈសំខាន់ៗ | ចំនួនសមាជិកសហគមន៍កសិកម្មបានចូលរួមសរុប (នាក់) | ចំនួនសមាជិកសហគមន៍កសិកម្មសរុប (នាក់) |
|---|---|---|---|
| **លើកទី1** ថ្ងៃទី15 ខែកក្កដា ឆ្នាំ2015 | 1.សមាជិកជំពាក់ប្រាក់មិនសង<br>2.ជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាលថ្មី<br>3.ជួសជុលការិយាល័យ<br>4.ការចុះកិច្ចសន្យាជំនួញជាមួយក្រុមហ៊ុនឯកជន | 80 | 120 |
| លើកទី2 ថ្ងៃទី...... ខែ......... ឆ្នាំ201... | 1.<br>2.<br>3. | | |

### 2.1.3 ប្រជុំក្រុមប្រឹក្សាភិបាល

| ប្រជុំ | **ឆ្នាំ2014 គិតពីថ្ងៃទី *** **(1-មករា-2014 ដល់31-ធ្នូ-2014)** | ឆ្នាំ2015 គិតពីថ្ងៃទី ** (1-មករា-2015 ដល់31-ធ្នូ-2015) |
|---|---|---|
| | ចំនួនប្រជុំសរុប (ដង) | ចំនួនប្រជុំសរុប(ដង) |
| ក្រុមប្រឹក្សាភិបាល | 12 | 12 |

### 2.1.4 ប្រជុំគណៈកម្មាធិការត្រួតពិនិត្យ

| ប្រជុំ | ឆ្នាំ2014 គិតពីថ្ងៃទី (1-មករា-2014 ដល់31-ធ្នូ-2014) | ឆ្នាំ2015 គិតពីថ្ងៃទី (1-មករា-2015 ដល់31-ធ្នូ-2015) |
|---|---|---|
| | ចំនួនប្រជុំសរុប(ដង) | ចំនួនប្រជុំសរុប(ដង) |
| គណៈកម្មាធិការត្រួតពិនិត្យ | 5 | 6 |

**ចំណាំ៖**

***ឆ្នាំ2014 គិតពីថ្ងៃទី (1-មករា-2014 ដល់31-ធ្នូ-2014)** } មានន័យថា គេគិតតែពីសកម្មភាពដែលកើតមានឡើងតែនៅក្នុងរយៈពេលពេញមួយឆ្នាំ2014 (ឧទាហរណ៍៖ នៅក្នុងឆ្នាំ2014 គិតពីថ្ងៃទី1-មករា-2014 ដល់ថ្ងៃទី31-ធ្នូ-2014 កិច្ចប្រជុំក្រុមប្រឹក្សាភិបាលសរុបមានចំនួន12ដង)។

****ឆ្នាំ2015 គិតពីថ្ងៃទី (1-មករា-2015 ដល់31-ធ្នូ-2015)** } មានន័យថា គេគិតតែពីសកម្មភាពដែលកើតមានឡើងតែនៅក្នុងរយៈពេលពេញមួយឆ្នាំ2015 (ឧទាហរណ៍៖ នៅក្នុងឆ្នាំ2015 គិតពីថ្ងៃទី1-មករា-2015 ដល់ថ្ងៃទី31-ធ្នូ-2015 កិច្ចប្រជុំក្រុមប្រឹក្សាភិបាលសរុបមានចំនួន12ដង)។

## 3. **រចនាសម្ព័ន្ធគ្រប់គ្រងរបស់សហគមន៍កសិកម្ម**

### **3.1 ព័ត៌មានសមាជិកសហគមន៍កសិកម្ម**

| បរិយាយ | ឆ្នាំ2014 ត្រឹមថ្ងៃទី 31-ធ្នូ 2014 | | **ឆ្នាំ2015 *** ត្រឹមថ្ងៃទី 31-ធ្នូ-2015** | | % ប្រែប្រួលសរុប **** |
|---|---|---|---|---|---|
| | ចំនួនសរុប (នាក់) | ស្រី | ចំនួនសរុប (នាក់) | ស្រី | |
| សមាជិកសហគមន៍កសិកម្ម | 90 | 70 | 120 | 75 | 33% |

### 3.2 ព័ត៌មានថ្នាក់ដឹកនាំ (ក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ)

| បរិយាយ | ឆ្នាំ2014 ត្រឹមថ្ងៃទី 31-ធ្នូ 2014 | | ឆ្នាំ2015 ត្រឹមថ្ងៃទី 31-ធ្នូ-2015 | | % ប្រែប្រួលសរុប |
|---|---|---|---|---|---|
| | ចំនួនសរុប (នាក់) | ស្រី | ចំនួនសរុប (នាក់) | ស្រី | |
| ក្រុមប្រឹក្សាភិបាល | 5 | 3 | 5 | 3 | 0% |
| គណៈកម្មាធិការត្រួតពិនិត្យ | 3 | 2 | 3 | 2 | 0% |

### 3.3 បុគ្គលិកជួលពីខាងក្រៅ

| បរិយាយ | ឆ្នាំ2014 ត្រឹមថ្ងៃទី 31-ធ្នូ 2014 | | ឆ្នាំ2015 ត្រឹមថ្ងៃទី 31-ធ្នូ-2015 | | % ប្រែប្រួលសរុប |
|---|---|---|---|---|---|
| | ចំនួនសរុប (នាក់) | ស្រី | ចំនួនសរុប (នាក់) | ស្រី | |
| នាយកគ្រប់គ្រង | 1 | 0 | 1 | 0 | 0% |
| បុគ្គលិកជាប់កិច្ចសន្យា | 2 | 1 | 2 | 1 | 0% |

### 3.4 ព័ត៌មានភាគហ៊ុន

| បរិយាយ | ឆ្នាំ2014 ត្រឹមថ្ងៃទី 31-ធ្នូ 2014 | ឆ្នាំ2015 ត្រឹមថ្ងៃទី 31-ធ្នូ-2015 | % ប្រែប្រួល |
|---|---|---|---|
| ចំនួនភាគហ៊ុនសរុប (ហ៊ុន) | 500 | 1,000 | 100% |
| តម្លៃក្នុង1ភាគហ៊ុន (រៀល) | 50,000 រៀល | 50,000 រៀល | 0% |
| តម្លៃភាគហ៊ុនសរុប (រៀល) | 25,000,000 រៀល | 50,000,000 រៀល | 100% |

* * ***ចំណាំ៖ ឆ្នាំ2015 ត្រឹមថ្ងៃទី 31-ធ្នូ-2015** មានន័យថា នៅពេលបិទបញ្ជីចុងឆ្នាំត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2015 តើមានសមាជិកប៉ុន្មាន ឬនៅសល់ប៉ុន្មាន? ឧទាហរណ៍៖ ឆ្នាំ2015 ត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2015 សមាជិកសហគមន៍កសិកម្មសរុបមានចំនួន120នាក់។

* * * ***ចំពោះ % ប្រែប្រួល** ៖ ប្រើសម្រាប់ដឹងពីកម្រិតប្រែប្រួលរវាងឆ្នាំចាស់(2014) និងឆ្នាំថ្មី(2015) តើមានការកើនឡើង ឬថយចុះប៉ុន្មាន?

**រូបមន្ត % ប្រែប្រួល** = $\frac{\text{(ឆ្នាំថ្មី - ឆ្នាំចាស់)}}{\text{ឆ្នាំចាស់}}$ x 100 = …………%

**ឧទាហរណ៍ % ប្រែប្រួលនៃសមាជិកសហគមន៍កសិកម្ម** = $\frac{(120 - 90)}{90} \times 100 = 33\%$

## 4. សកម្មភាពអប់រំរបស់សហគមន៍កសិកម្ម

☞☛ គ្រប់សកម្មភាពអប់រំទាំងអស់ ដែលបណ្តុះបណ្តាលដោយសហគមន៍ខ្លួនឯង ឬទទួលការបណ្តុះបណ្តាលពីខាងក្រៅ ត្រូវតែកត់បញ្ចូលក្នុងតារាង។

### 4.1 ក្រុមប្រឹក្សាភិបាល

| ប្រធានបទ | ចំនួនក្រុមប្រឹក្សាភិបាលបានចូលរួម (នាក់) | វគ្គបណ្តុះបណ្តាល/ទស្សនកិច្ច | |
|---|---|---|---|
| | | ក្នុងប្រទេស | ក្រៅប្រទេស |
| វគ្គបណ្តុះបណ្តាលស្តីពី ភាពជាអ្នកដឹកនាំ | 2 | ✓ | |
| វគ្គបណ្តុះបណ្តាលស្តីពី គណនេយ្យ | 2 | ✓ | |
| ទស្សនៈកិច្ចពីការចិញ្ចឹមមាន់ | 3 | ✓ | |

### 4.2 គណៈកម្មាធិការត្រួតពិនិត្យ

| ប្រធានបទ | ចំនួនគណៈកម្មាធិការត្រួតពិនិត្យបានចូលរួម(នាក់) | វគ្គបណ្តុះបណ្តាល/ទស្សនកិច្ច | |
|---|---|---|---|
| | | ក្នុងប្រទេស | ក្រៅប្រទេស |
| វគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យសហគមន៍កសិកម្ម | 1 | ✓ | |

### 4.3 សមាជិកសហគមន៍កសិកម្ម

| ប្រធានបទ | ចំនួនសមាជិកបានចូលរួម (នាក់) | វគ្គបណ្តុះបណ្តាល/ទស្សនកិច្ច | |
|---|---|---|---|
| | | ក្នុងប្រទេស | ក្រៅប្រទេស |
| វគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹមមាន់ | 30 | ✓ | |
| វគ្គបណ្តុះបណ្តាលស្តីពីការដាំផ្សិត | 25 | ✓ | |

## 5. ទ្រព្យសម្បត្តិសហគមន៍កសិកម្ម

### 5.1 ទ្រព្យសម្បត្តិ

| បរិយាយ | ថ្លៃដើម(រៀល) | កំណត់សម្គាល់ |
|---|---|---|
| 1.ដី | 20,000,000 | 20m x 50 m |
| 2. អគារការិយាល័យ | 40,000,000 | 4m x 6m |
| 3. ឧបករណ៍ការិយាល័យ | 3,400,000 | តុ កៅអី កុំព្យូទ័រ ទូដាក់ឯកសារ.... |
| 4.ឧបករណ៍កសិកម្ម | | |
| 4.1 ត្រាក់ទ័រ | 20,000,000 | 1គ្រឿង |
| 4.2.ម៉ាស៊ីនបូមទឹក | 4,000,000 | 1គ្រឿង |

## 6. មុខរបរ ឬ មុខជំនួញរបស់សហគមន៍កសិកម្ម

### 6.1 មុខរបរឥណទាន

6.1.1ប្រាក់បញ្ញើសន្សំ

ក. ប្រាក់បញ្ញើសន្សំរបស់សមាជិកនិងអ្នកមិនមែនសមាជិកសហគមន៍កសិកម្ម

(នៅសល់ក្នុងសហគមន៍ពេលបិទបញ្ជីត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2014 និង2015)

| បរិយាយ | ចំនួនទឹកប្រាក់ (រៀល) | | % ប្រែប្រួល |
|---|---|---|---|
| | ឆ្នាំ2014 ត្រឹមថ្ងៃទី 31-ធ្នូ 2014(រៀល) | ឆ្នាំ2015 ត្រឹមថ្ងៃទី 31-ធ្នូ-2015(រៀល) | |
| ប្រាក់បញ្ញើសន្សំរបស់សមាជិកសហគមន៍កសិកម្ម | 4,000,000 | 8,000,000 | 100% |
| ប្រាក់បញ្ញើសន្សំរបស់អ្នកមិនមែនសមាជិកសហគមន៍កសិកម្ម | 1,000,000 | 2,000,000 | 100% |
| **សរុបប្រាក់បញ្ញើសន្សំរបស់សមាជិក និងអ្នកមិនមែនសមាជិកសហគមន៍កសិកម្ម** | 5,000,000 | 10,000,000 | 100% |

ខ. ប្រាក់បញ្ញើសន្សំធម្មតា និងប្រាក់បញ្ញើសន្សំមានកាលកំណត់ពីសមាជិកនិងអ្នកមិនមែនសមាជិកសហគមន៍កសិកម្ម (នៅសល់ក្នុងសហគមន៍ពេលបិទបញ្ជីត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2014 និង2015)

| បរិយាយ | ចំនួនទឹកប្រាក់ (រៀល) | | % ប្រែប្រួល |
|---|---|---|---|
| | ឆ្នាំ2014 ត្រឹមថ្ងៃទី 31-ធ្នូ 2014 (រៀល) | ឆ្នាំ2015 ត្រឹមថ្ងៃទី 31-ធ្នូ-2015 (រៀល) | |
| ប្រាក់បញ្ញើសន្សំធម្មតា | 3,000,000 | 6,000,000 | 100% |
| ប្រាក់បញ្ញើសន្សំមានកាលកំណត់ | 2,000,000 | 4,000,000 | 100% |
| **សរុបប្រាក់បញ្ញើសន្សំធម្មតា និងប្រាក់បញ្ញើសន្សំមានកាលកំណត់** | 5,000,000 | 10,000,000 | 100% |

6.1.2 ប្រាក់យកទៅផ្ញើនៅធនាគារ (នៅសល់ពេលបិទបញ្ជីត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2014 និង2015)

| បរិយាយ | ចំនួនទឹកប្រាក់(រៀល) | | % ប្រែប្រួល |
|---|---|---|---|
| | ឆ្នាំ2014 ត្រឹមថ្ងៃទី 31-ធ្នូ-2014 | ឆ្នាំ2015 ត្រឹមថ្ងៃទី 31-ធ្នូ-2015 | |
| ប្រាក់យកទៅផ្ញើនៅធនាគារ | 5,000,000 | 10,000,000 | 100% |

6.1.3 ប្រាក់ឱ្យសមាជិកនិងអ្នកមិនមែនសមាជិកសហគមន៍កសិកម្មខ្ចី (ធ្វើឥណទាន)

(ចំនួនប្រាក់ឱ្យសមាជិកនិងអ្នកមិនមែនសមាជិកសហគមន៍កសិកម្មខ្ចីដែលនៅជំពាក់មិនទាន់បានសងអស់ នៅពេលបិទបញ្ជីថ្ងៃទី31 ខែធ្នូ ឆ្នាំ2014 និង2015) ។

| បរិយាយ | ចំនួនទឹកប្រាក់(រៀល) | | % ប្រែប្រួល |
|---|---|---|---|
| | ឆ្នាំ2014 ត្រឹមថ្ងៃទី 31-ធ្នូ-2014 | ឆ្នាំ2015 ត្រឹមថ្ងៃទី 31-ធ្នូ-2015 | |
| ប្រាក់ឱ្យសមាជិកសហគមន៍កសិកម្មខ្ចី (នៅជំពាក់មិនទាន់បានសង) | 15,000,000 | 45,000,000 | 200% |
| ប្រាក់ឱ្យអ្នកមិនមែនសមាជិកសហគមន៍កសិកម្មខ្ចី (នៅជំពាក់មិនទាន់បានសង) | 10,000,000 | 5,000,000 | -50%(◈) |
| **ប្រាក់ឱ្យគេខ្ចីសរុប** | 25,000,000 | 50,000,000 | 100% |

(◈) -50% បានន័យថាប្រាក់ឱ្យអ្នកមិនមែនសមាជិកសហគមន៍កសិកម្មខ្ចីនៅជំពាក់មិនទាន់បានសង ក្នុងឆ្នាំ2015 តិចជាងឆ្នាំ 2014 ចំនួន 50% ។ តាមតារាងខាងលើ កាលបិទបញ្ជីឆ្នាំ 2014 អ្នកមិនមែនសមាជិកនៅជំពាក់ដល់ទៅ 10,000,000 ប៉ុន្តែពេលបិទបញ្ជីឆ្នាំ 2015 នៅជំពាក់ត្រឹម 5,000,000 រៀល។

**6.2 មុខរបរផ្គត់ផ្គង់** (ជាមុខរបរមួយដែលទិញធាតុចូលកសិកម្ម សម្ភារៈកសិកម្ម គ្រឿងឧបភោគ បរិភោគ ទំនិញ ពីខាងក្រៅមកលក់ឱ្យសមាជិកសហគមន៍កសិកម្ម និងអ្នកមិនមែនសមាជិកសហគមន៍កសិកម្ម ) ។ ចំនួនប្រាក់ចំណូលសរុបបានមកពីការផ្គត់ផ្គង់ធាតុចូលកសិកម្ម និងទំនិញផ្សេងៗទៀតក្នុងរយៈពេលពេញមួយឆ្នាំមានដូចខាងក្រោម៖

6.2.1 ផ្គត់ផ្គង់ជីកសិកម្មដល់សមាជិក

| បរិយាយ | ចំនួន | | | | % ប្រែប្រួល (រៀល) |
|---|---|---|---|---|---|
| | ឆ្នាំ2014 គិតពីថ្ងៃទី (1-មករា-2014 ដល់31-ធ្នូ-2014) | | ឆ្នាំ2015 គិតពីថ្ងៃទី (1-មករា-2015 ដល់31-ធ្នូ-2015) | | |
| ចំណូលសរុបពីផ្គត់ផ្គង់ជីកសិកម្ម | តោន | រៀល | តោន | រៀល | |
| | 10 | 10,000,000 | 13 | 14,000,000 | 40% |

6.2.2 ផ្គត់ផ្គង់ចំណីសត្វដល់សមាជិក

| បរិយាយ | ចំនួន | | | | % ប្រែប្រួល (រៀល) |
|---|---|---|---|---|---|
| | ឆ្នាំ2014 គិតពីថ្ងៃទី (1-មករា-2014 ដល់31-ធ្នូ-2014) | | ឆ្នាំ2015 គិតពីថ្ងៃទី (1-មករា-2015 ដល់31-ធ្នូ-2015) | | |
| ចំណូលសរុបពីផ្គត់ផ្គង់ចំណីសត្វ | គីឡូក្រាម | រៀល | គីឡូក្រាម | រៀល | |
| | 857 | 3,000,000 | 857 | 3,000,000 | 0% |

6.2.3 ផ្គត់ផ្គង់ថ្នាំកសិកម្មដល់សមាជិក

| បរិយាយ | ចំនួន | | | | % ប្រែប្រួល (រៀល) |
|---|---|---|---|---|---|
| | ឆ្នាំ2014 គិតពីថ្ងៃទី (1-មករា-2014 ដល់31-ធ្នូ-2014) | | ឆ្នាំ2015 គិតពីថ្ងៃទី (1-មករា-2015 ដល់31-ធ្នូ-2015) | | |
| ចំណូលសរុបពីផ្គត់ផ្គង់ថ្នាំកសិកម្ម | លីត្រ | រៀល | លីត្រ | រៀល | |
| | 100 | 1,000,000 | 200 | 2,000,000 | 100% |

6.2.4 ផ្គត់ផ្គង់ពូជស្រូវដល់សមាជិក

| បរិយាយ | ចំនួន | | | | % ប្រែប្រួល (រៀល) |
|---|---|---|---|---|---|
| | ឆ្នាំ2014 គិតពីថ្ងៃទី (1-មករា-2014 ដល់31-ធ្នូ-2014) | | ឆ្នាំ2015 គិតពីថ្ងៃទី (1-មករា-2015 ដល់31-ធ្នូ-2015) | | |
| ចំណូលសរុបពីផ្គត់ផ្គង់ពូជស្រូវ | តោន | រៀល | តោន | រៀល | |
| | 3.75 | 15,000,000 | 5 | 20,000,000 | 33% |

6.2.5 ផ្គត់ផ្គង់ទងជំឡូងឈ្វាដល់សមាជិក

| បរិយាយ | ចំនួន | | | | % ប្រែប្រួល (រៀល) |
|---|---|---|---|---|---|
| | ឆ្នាំ2014 គិតពីថ្ងៃទី (1-មករា-2014 ដល់31-ធ្នូ-2014) | | ឆ្នាំ2015 គិតពីថ្ងៃទី (1-មករា-2015 ដល់31-ធ្នូ-2015) | | |
| ចំណូលសរុបពីផ្គត់ផ្គង់ទងជំឡូងឈ្វា | ទង | រៀល | ទង | រៀល | |
| | 12,000 | 6,000,000 | 20,000 | 9,000,000 | 50% |

6.2.6 មុខរបរផ្គត់ផ្គង់ផ្សេងៗ

| បរិយាយ | ចំនួន | | | | % ប្រែប្រួល (រៀល) |
|---|---|---|---|---|---|
| | ឆ្នាំ2014 គិតពីថ្ងៃទី (1-មករា-2014 ដល់31-ធ្នូ-2014) | | ឆ្នាំ2015 គិតពីថ្ងៃទី (1-មករា-2015 ដល់31-ធ្នូ-2015) | | |
| | ឯកតា ❀ | រៀល | ឯកតា | រៀល | |
| ………………… | ………… | ………………………… | ………… | ………………………… | ………% |

❀ (ឯកតា បើប្រើជញ្ជីងថ្លឹង ត្រូវគិតជា តោន។ បើប្រើរង្វាស់រង្វាល់ ត្រូវគិតជា លីត្រ ។ល។)

**6.3 មុខរបរទីផ្សារ** (ប្រមូលផលិតផលកសិកម្មពីសមាជិកសហគមន៍កសិកម្ម យកទៅលក់នៅទីផ្សារ) ចំនួនបរិមាណលក់នៅទីផ្សារឬឈ្មួញកណ្តាល ។ល។ ក្នុងរយៈពេលពេញមួយឆ្នាំដូចខាងក្រោម៖

6.3.1 មុខរបរលក់ស្រូវ (ប្រមូលទិញស្រូវពីសមាជិកលក់ទៅទីផ្សារ)

| បរិយាយ | ចំនួន | | | | % ប្រែប្រួល (រៀល) |
|---|---|---|---|---|---|
| | ឆ្នាំ2014 គិតពីថ្ងៃទី (1-មករា-2014 ដល់31-ធ្នូ-2014) | | ឆ្នាំ2015 គិតពីថ្ងៃទី (1-មករា-2015 ដល់31-ធ្នូ-2015) | | |
| ចំណូលសរុបពីលក់ស្រូវ | តោន | រៀល | តោន | រៀល | |
| | 50 | 40,000,000 | 50 | 40,000,000 | 0% |

6.3.2 មុខរបរ លក់អង្ករ (ប្រមូលទិញស្រូវពីសមាជិក កិនចេញជាអង្កររួចលក់ទៅទីផ្សារ)

| បរិយាយ | ចំនួន | | | | % ប្រែប្រួល (រៀល) |
|---|---|---|---|---|---|
| | ឆ្នាំ2014 គិតពីថ្ងៃទី (1-មករា-2014 ដល់31-ធ្នូ-2014) | | ឆ្នាំ2015 គិតពីថ្ងៃទី (1-មករា-2015 ដល់31-ធ្នូ-2015) | | |
| ចំណូលសរុបពីលក់អង្ករ | តោន | រៀល | តោន | រៀល | |
| | 15 | 24,000,000 | 10 | 16,000,000 | -33% |

### 6.3.3 មុខរបរ លក់បន្លែ (ប្រមូលទិញបន្លែពីសមាជិកលក់ទៅទីផ្សារ)

| បរិយាយ | ចំនួន | | | | % ប្រែប្រួល (រៀល) |
|---|---|---|---|---|---|
| | ឆ្នាំ2014 គិតពីថ្ងៃទី (1-មករា-2014 ដល់31-ធ្នូ-2014) | | ឆ្នាំ2015 គិតពីថ្ងៃទី (1-មករា-2015 ដល់31-ធ្នូ-2015) | | |
| ចំណូលសរុបពី លក់បន្លែសាឡាត់ | គីឡូក្រាម | រៀល | គីឡូក្រាម | រៀល | |
| | 500 | 1,500,000 | 500 | 1,500,000 | 0% |

### 6.3.4 មុខរបរលក់សត្វ (ប្រមូលទិញសត្វពីសមាជិកលក់ទៅទីផ្សារ)

| បរិយាយ | ចំនួន | | | | % ប្រែប្រួល (រៀល) |
|---|---|---|---|---|---|
| | ឆ្នាំ2014 គិតពីថ្ងៃទី (1-មករា-2014 ដល់31-ធ្នូ-2014) | | ឆ្នាំ2015 គិតពីថ្ងៃទី (1-មករា-2015 ដល់31-ធ្នូ-2015) | | |
| ចំណូលសរុបពី លក់មាន់ | គីឡូក្រាម | រៀល | គីឡូក្រាម | រៀល | |
| | 400 | 4,800,000 | 150 | 1,800,000 | -62.5% |

### 6.3.5 មុខរបរលក់ស្វាយ (ប្រមូលទិញស្វាយពីសមាជិកលក់ទៅទីផ្សារ)

| បរិយាយ | ចំនួន | | | | % ប្រែប្រួល (រៀល) |
|---|---|---|---|---|---|
| | ឆ្នាំ2014 គិតពីថ្ងៃទី (1-មករា-2014 ដល់31-ធ្នូ-2014) | | ឆ្នាំ2015 គិតពីថ្ងៃទី (1-មករា-2015 ដល់31-ធ្នូ-2015) | | |
| ចំណូលសរុបពី ផលិតផលស្វាយ | តោន | រៀល | តោន | រៀល | |
| | 5 | 10,000,000 | 5 | 10,000,000 | 0% |

### 6.3.6 មុខរបរលក់អំពៅ (ប្រមូលទិញអំពៅពីសមាជិកលក់ទៅទីផ្សារ)

| បរិយាយ | ចំនួន | | | | % ប្រែប្រួល (រៀល) |
|---|---|---|---|---|---|
| | ឆ្នាំ2014 គិតពីថ្ងៃទី (1-មករា-2014 ដល់31-ធ្នូ-2014) | | ឆ្នាំ2015 គិតពីថ្ងៃទី (1-មករា-2015 ដល់31-ធ្នូ-2015) | | |
| ចំណូលសរុបពីលក់ អំពៅ | បាច់ | រៀល | បាច់ | រៀល | |
| | 750 | 3,000,000 | 750 | 3,000,000 | 0% |

6.3.7 មុខរបរទីផ្សារផ្សេងៗ

| បរិយាយ | ចំនួន | | | | % ប្រែប្រួល (រៀល) |
|---|---|---|---|---|---|
| | ឆ្នាំ2014 គិតពីថ្ងៃទី (1-មករា-2014 ដល់31-ធ្នូ-2014) | | ឆ្នាំ2015 គិតពីថ្ងៃទី (1-មករា-2015 ដល់31-ធ្នូ-2015) | | |
| ចំណូលសរុបពីមុខរបរទីផ្សារផ្សេងៗ | ឯកតា ❀ | រៀល | ឯកតា | រៀល | |
| | ………… | ………………………… | ………… | ………………………… | ………% |

❀ (ឯកតា បើប្រើជញ្ជីងថ្លឹង ត្រូវគិតជា តោន។ បើប្រើរង្វាស់រង្វាល់ ត្រូវគិតជា លីត្រ។)

**6.4 មុខរបរសេវាប្រើប្រាស់រួមគ្នា** (ជាមុខរបរមួយដែលផ្តល់សេវាកម្មឱ្យសមាជិក ឧ. សមាជិកប្រើប្រាស់ត្រាក់ទ័ររបស់សហគមន៍កសិកម្ម ដើម្បីធ្វើដីស្រែចំការរបស់គាត់ ហើយសហគមន៍យកថ្លៃឈ្នួលពីការជួលត្រាក់ទ័រ ឬគ្រឿងចក្រផ្សេងៗឱ្យសមាជិក)

| បរិយាយ | ចំនួនទឹកប្រាក់(រៀល) | | % ប្រែប្រួល (រៀល) |
|---|---|---|---|
| | ឆ្នាំ2014 គិតពីថ្ងៃទី (1-មករា-2014 ដល់31-ធ្នូ-2014) | ឆ្នាំ2015 គិតពីថ្ងៃទី (1-មករា-2015 ដល់31-ធ្នូ-2015) | |
| ចំណូលពីការភ្ជួរដីស្រែចំការ | 8,000,000 | 10,000,000 | 25% |

**6.5 មុខរបរផ្សេងៗ**

| បរិយាយ | ចំនួនទឹកប្រាក់(រៀល) | | % ប្រែប្រួល (រៀល) |
|---|---|---|---|
| | ឆ្នាំ2014 គិតពីថ្ងៃទី (1-មករា-2014 ដល់31-ធ្នូ-2014) | ឆ្នាំ2015 គិតពីថ្ងៃទី (1-មករា-2015 ដល់31-ធ្នូ-2015) | |
| ចំណូលពីមុខរបរផ្សេងៗ | ……………………………… | ……………………………. | ………% |

## 7. របាយការណ៍លទ្ធផល " ចំណេញ/(ខាត)"

(ប្រាក់ចំណេញ = ចំណូលសរុប - ចំណាយសរុប)

1. ***ចំណេញដុលសរុបពីមុខរបរទាំងអស់ = 25,600,000 (មិនទាន់ដកចំណាយរដ្ឋបាលសរុបរបស់សហគមន៍)***

= ចំណេញពីមុខរបរឥណទាន (1.1) + ចំណេញពីមុខរបរផ្គត់ផ្គង់ (1.2) + ចំណេញពីមុខរបរទីផ្សារ (1.3 )+ចំណេញពីមុខរបរសេវាប្រើប្រាស់រួមគ្នា (1.4) + ចំណេញពីមុខរបរផ្សេងៗ (1.5) ( ***សូមមើលតារាងខាងក្រោម***)

= **9,300,000**(1.1) + **8,000,000** (1.2) + **4,300,000** (1.3 )+ **4,000,000** (1.4) + 0 (1.5)= **25,600,000**

*A ចំណេញសុទ្ធពីមុខរបរ* = ចំណេញដុលសរុបពីមុខរបរទាំងអស់ *1* - ចំណាយរដ្ឋបាលសរុប *2*

*B ចំណេញមុនកាត់ពន្ធក្នុងគ្រា* = ចំណេញសុទ្ធពីមុខរបរ *A + ចំណេញក្រៅពីមុខរបរ (3)* - ចំណាយក្រៅពីមុខរបរ *(4) + ចំណេញពិសេស (5)* - កំហាតពិសេស *(6)*

(A) ***ប្រាក់ចំណេញសុទ្ធក្នុងគ្រា*** = ចំណេញមុនកាត់ពន្ធក្នុងគ្រា *B* – ពន្ធលើប្រាក់ចំណេញ *(7)*

⟹ **ប្រាក់ចំណេញសុទ្ធក្នុងគ្រា** *ជា* **ប្រាក់ចំណេញមិនទាន់បែងចែក**

ត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2015

| បរិយាយ | ចំនួនប្រាក់ ចំណូល ឬ ចំណាយ | ចំនួនប្រាក់ចំណេញ |
|---|---|---|
| ***1-ចំណេញដុលសរុបពីមុខរបរទាំងអស់*** | | ( 1.1+1.2+1.3+1.4 ) = ***25,600,000*** |
| 1.1- មុខរបរឥណទាន | | |
| សរុបការប្រាក់ពីមុខរបរឥណទាន(ក) | ***19,300,000*** | |
| -ការប្រាក់នៃប្រាក់ផ្ញើធនាគារ | 1,000,000 | |
| -ការប្រាក់នៃប្រាក់ឱ្យគេខ្ចី | 18,300,000 | |
| សរុបចំណាយលើមុខរបរឥណទាន(ខ) | ***10,000,000*** | |
| -ចំណាយលើមុខរបរឥណទាន | 2,000,000 | |
| -ចំណាយលើការប្រាក់បញ្ញើសន្សំ | 3,000,000 | |
| -ចំណាយលើការប្រាក់នៃប្រាក់កម្ចី | 5,000,000 | |
| ***ចំណេញពីមុខរបរឥណទាន = (ក) - (ខ)*** | | ***(1.1) = 9,300,000*** |
| 1.2 មុខរបរផ្គត់ផ្គង់ | | |
| ចំណូលដុលសរុបពីមុខរបរផ្គត់ផ្គង់ (គ) | 48,000,000 | |
| ចំណាយសរុបលើមុខរបផ្គត់ផ្គង់ (ឃ) | 40,000,000 | |
| ***ចំណេញពីមុខរបរ ផ្គត់ផ្គង់ = (គ) - (ឃ)*** | | ***(1.2) = 8,000,000*** |

| | | |
|---|---|---|
| 1.3 មុខរបរទីផ្សារ | | |
| ចំណូលដុលសរុបពីមុខរបរទីផ្សារ ( ង ) | 72,300,000 | |
| ចំណាយសរុបលើមុខរបរទីផ្សារ ( ច ) | 68,000,000 | |
| *ចំណេញពីមុខរបរទីផ្សារ = ( ង ) - ( ច )* | | **(1.3) = 4,300,000** |
| 1.4 មុខរបរសេវាប្រើប្រាស់រួមគ្នា | | |
| ចំណូលដុលសរុបពីមុខរបរសេវាប្រើប្រាស់រួមគ្នា ( ឆ ) | 10,000,000 | |
| ចំណាយសរុបលើមុខរបរសេវាប្រើប្រាស់រួមគ្នា( ជ ) | 6,000,000 | |
| *ចំណេញពីមុខរបរសេវាប្រើប្រាស់រួមគ្នា= ( ឆ ) - ( ជ )* | | **(1.4) = 4,000,000** |
| 1.5 មុខរបរផ្សេងៗ | | |
| ចំណូលដុលសរុបពីមុខរបរផ្សេងៗ( ឈ ) | 0 | |
| ចំណាយសរុបលើមុខរបរផ្សេងៗ ( ញ ) | 0 | |
| *ចំណេញពីមុខរបរផ្សេងៗ = ( ឈ ) - ( ញ )* | | **(1.5) = 0** |
| *2-ចំណាយរដ្ឋបាលសរុប* | ***7,000,000*** | |
| ចំណាយលើបុគ្គលិក | 3,000,000 | |
| ចំណាយលើការធ្វើដំណើរ | 1,000,000 | |
| ចំណាយលើការជួលអគារ | 1,000,000 | |
| ចំណាយលើរំលស់ទ្រព្យសកម្មរយៈពេលវែង | 2,000,000 | |
| *ចំណេញសុទ្ធពីមុខរបរ A = 1 - 2* | | **18,600,000** |
| *3- ចំណេញក្រៅពីមុខរបរ (3)* | | 0 |
| 4- ចំណាយក្រៅពីមុខរបរ (4) | 0 | |
| *5-ចំណេញពិសេស (5)* | | **4,000,000** |
| 6-កំហាតពិសេស (6) | 0 | |
| *ចំណេញមុនកាត់ពន្ធក្នុងគ្រា* B<br>B = A+(3) - (4) +(5) -(6) | | **22,600,000** |
| 7-ពន្ធលើប្រាក់ចំណេញ (7) | 0 | |
| *ចំណេញសុទ្ធក្នុងគ្រា* C = *B – (7)* | | **22,600,000** |
| *ប្រាក់ចំណេញមិនទាន់បែងចែក* | | **22,600,000** |

## 8. ការបែងចែកប្រាក់ចំណេញ

| បរិយាយ | ឆ្នាំ 2015<br>ត្រឹមថ្ងៃទី 31-ធ្នូ 2015 |
|---|---|
| ប្រាក់ចំណេញមិនទាន់បែងចែក | **22,600,000** |
| -មូលនិធិបំរុង (20%) | 4,520,000 |
| -មូលនិធិបណ្តុះបណ្តាល (3%) | 678,000 |
| -មូលនិធិស្ម័គ្រចិត្តសម្រាប់អភិវឌ្ឍន៍សហគមន៍កសិកម្ម (ដើម្បីពង្រីកមុខរបរ) | 998,000 |
| -មូលនិធិលើកទឹកចិត្តសមាជិកដែលប្រើប្រាស់ជំនួញសហគមន៍ | 499,000 |
| -ប្រាក់ភាគលាភធៀបតម្លៃភាគហ៊ុន ※ | 7,500,000 |
| -ប្រាក់លើកទឹកចិត្តសម្រាប់ប្រធានក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ និងសមាជិកក្នុងជួរថ្នាក់ដឹកនាំ | 1,715,000 |
| -ប្រាក់ចំណេញរក្សាទុក | 6,690,000 |

**<u>ចំណាំ</u>**៖ សហគមន៍កសិកម្មត្រូវដក 20%សម្រាប់មូលនិធិបំរុង និង 3%សម្រាប់មូលនិធិបណ្តុះបណ្តាលដែលកំណត់ដោយច្បាប់ស្តីពីសហគមន៍កសិកម្ម ហើយសហគមន៍កសិកម្មអាចធ្វើការសម្រេចចិត្តបែងចែកប្រាក់ដែលនៅសល់ទៅតាមការអនុម័តរបស់មហាសន្និបាតនូវចំណុច ដូចជាមូលនិធិស្ម័គ្រចិត្តសម្រាប់អភិវឌ្ឍន៍សហគមន៍កសិកម្ម(សម្រាប់ទិញឧបករណ៍ប្រើប្រាស់រួមក្នុងសហគមន៍) មូលនិធិលើកទឹកចិត្តសមាជិកដែលប្រើប្រាស់ជំនួញរបស់សហគមន៍ ប្រាក់ភាគលាភដល់សមាជិកតាមចំនួនភាគហ៊ុន ប្រាក់លើកទឹកចិត្តសម្រាប់ក្រុមប្រឹក្សាភិបាល និងសមាជិកគណៈកម្មាធិការត្រួតពិនិត្យ និងប្រាក់ចំណេញរក្សាទុក។

※ <u>ប្រាក់ភាគលាភធៀបតម្លៃភាគហ៊ុនៈ</u> គោលការណ៍សម្ព័ន្ធសហគមន៍អន្តរជាតិ(ICA)ស្នើឱ្យសហគមន៍ទាំងអស់បើកប្រាក់ភាគលាភធៀបតម្លៃភាគហ៊ុន "មានការកំណត់" ដល់សមាជិក។ សហគមន៍កសិកម្មមិនមែនជាអង្គការដែលផ្តល់ផលប្រយោជន៍ឱ្យសមាជិក ដោយត្រូវផ្តល់ប្រាក់ភាគលាភខ្ពស់ពេកទេ ។ សហគមន៍កសិកម្មគឺជាអង្គការដែលផ្តល់ផលប្រយោជន៍ដល់សមាជិកដោយផ្តល់សេវាកម្មសមស្របតាមរយៈការប្រកបមុខរបររបស់សមាជិកទាំងនោះ។ សហគមន៍ត្រូវតែផ្តល់ការប្រាក់ទាបជាងធនាគារឯកជនចំពោះសមាជិកដែលខ្ចីប្រាក់ និងផ្តល់ការប្រាក់ខ្ពស់ជាងស្ថាប័នមីក្រូហិរញ្ញវត្ថុ ឬធនាគារឯកជនដល់សមាជិកដែលដាក់ប្រាក់បញ្ញើសន្សំក្នុងសហគមន៍កសិកម្ម។

សហគមន៍កសិកម្មត្រូវផ្គត់ផ្គង់ជីជូនសមាជិកក្នុងតម្លៃទាបជាងរោងចក្រ ឬហាងលក់ឯកជនជំនួសជាការផ្តល់ប្រាក់ភាគលាភច្រើនពេក។

សហគមន៍កសិកម្មមិនគួរផ្តល់ប្រាក់ភាគលាភធៀបភាគហ៊ុនលើសពី 15% នៃតម្លៃភាគហ៊ុននោះទេ។

ឧទាហរណ៍ថា ពេលតម្លៃភាគហ៊ុនក្នុង១ហ៊ុន ស្មើ១០ដុល្លារ នោះមានន័យថា សហគមន៍កសិកម្មមិនត្រូវផ្តល់ប្រាក់ភាគលាភធៀបនឹងភាគហ៊ុនលើសពី ១,៥ ដុល្លារទេ។

## 9. តារាងតុល្យការ

ទ្រព្យសកម្ម = បំណុល + ទុន

ត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2015

| **ទ្រព្យសកម្ម** | 2015 |
|---|---|
| **1.ទ្រព្យសកម្មរយៈពេលខ្លី** | |
| បេឡាសាច់ប្រាក់ | 200,000 |
| ប្រាក់ផ្ញើធនាគារ | 10,000,000 |
| ប្រាក់ឱ្យគេខ្ចី(ប្រាក់ឱ្យសមាជិកនិងមិនមែនសមាជិកខ្ចី ដែលនៅជំពាក់មិនទាន់បានសង) | 50,000,000 |
| ប្រាក់គេជំពាក់ត្រូវទារ( ជួលឧបករណ៍សហគមន៍ប្រើប្រាស់សម្រាប់ធ្វើស្រែចំការ) | 10,000,000 |
| ស្តុកទំនិញ (ប្រាក់ថ្លៃដើមជីឬទំនិញផ្សេងទៀត ដែលនៅសល់ក្នុងឃ្លាំង) | 17,000,000 |
| ប្រាក់គេជំពាក់ថ្លៃទំនិញ(ប្រាក់លក់ទំនិញឱ្យសមាជិកនិងមិនមែនសមាជិក ដែលនៅជំពាក់មិនទាន់បានសង) | 10,000,000 |
| ការប្រាក់នៃប្រាក់ឱ្យខ្ចីត្រូវទារ (ការប្រាក់ដែលសមាជិកនិងមិនមែនសមាជិកនៅជំពាក់មិនទាន់បានសង) | 10,000,000 |
| ប្រាក់កក់ថ្លៃទំនិញគេ (ប្រាក់បង់មុនឱ្យគេ មិនទាន់ទទួលទំនិញ) | 4,000,000 |
| **សរុបទ្រព្យសកម្មរយៈពេលខ្លី**(1) | ***111,200,000*** |
| **2.ទ្រព្យសកម្មរយៈពេលវែង** | |
| ដី | 20,000,000 |
| អគារការិយាល័យ | 40,000,000 |
| ឧបករណ៍ការិយាល័យ | 3,400,000 |
| ឧបករណ៍កសិកម្ម | |
| - ត្រាក់ទ័រ | 20,000,000 |
| - ម៉ាស៊ីនបូមទឹក | 4,000,000 |
| **សរុបទ្រព្យសកម្មរយៈពេលវែងមុនពេលរំលស់** | 87,400,000 |
| (ដក) រំលស់ទ្រព្យសកម្មរយៈពេលវែង | -7,000,000 |
| **សរុបទ្រព្យសកម្មរយៈពេលវែង**(2) | ***80,400,000*** |
| **សរុបទ្រព្យសកម្ម** (1)+(2) | ***191,600,000*** |

| **បំណុលនិងទុន** | 2015 |
| --- | --- |
| **1.បំណុល** | |
| ប្រាក់ខ្ចីពីខាងក្រៅ | 20,000,000 |
| ប្រាក់បញ្ញើសន្សំធម្មតា (ប្រាក់សន្សំដែលសមាជិកនិងមិនមែនសមាជិកនៅសល់ក្នុងសហគមន៍) | 6,000,000 |
| ប្រាក់បញ្ញើសន្សំមានកាលកំណត់ (ប្រាក់សន្សំដែលសមាជិកនិងមិនមែនសមាជិកនៅសល់ក្នុងសហគមន៍) | 4,000,000 |
| ប្រាក់ជំពាក់ទំនិញគេ (ប្រាក់ទិញទំនិញសមាជិកនិងមិនមែនសមាជិកជំពាក់មិនទាន់បានសង) | 61,000,000 |
| ការប្រាក់ត្រូវបង់(ការប្រាក់នៅជំពាក់សមាជិកឬអ្នកខាងក្រៅមិនទាន់បានសង) | 16,000,000 |
| ប្រាក់គេកក់ថ្លៃទំនិញ(ប្រាក់គេបង់ឱ្យមុន មិនទាន់ប្រគល់ទំនិញឱ្យគេ) | 14,714,000 |
| **សរុបបំណុល**(1) | ***121,714,000*** |
| **2.ទុន** | |
| ប្រាក់ភាគហ៊ុន | 50,000,000 |
| ប្រាក់សមាជិកភាព | 1,000,000 |
| មូលនិធិបម្រុង (បូកបន្តរៀងរាល់ឆ្នាំ) | 4,520,000 |
| មូលនិធិបណ្តុះបណ្តាល (បូកបន្តរៀងរាល់ឆ្នាំ) | 678,000 |
| មូលនិធិស្ម័គ្រចិត្តសម្រាប់អភិវឌ្ឍន៍សហគមន៍កសិកម្ម (បូកបន្តរៀងរាល់ឆ្នាំ) | 998,000 |
| ប្រាក់ចំណេញរក្សាទុក (បូកបន្តរៀងរាល់ឆ្នាំ) | 6,690,000 |
| ប្រាក់អំណោយបង្កើនទុនពីរដ្ឋ | 2,000,000 |
| ប្រាក់អំណោយបង្កើនទុនពីអ្នកផ្តល់ជំនួយ | 2,000,000 |
| ប្រាក់អំណោយបង្កើនទុនពីសប្បុរសជន | 2,000,000 |
| **សរុបទុន**(2) | ***69,886,000*** |
| **សរុបបំណុល និងទុន**(1)+(2) | **191,600,000** |

## 10. របាយការណ៍គណៈកម្មាធិការត្រួតពិនិត្យ

### 10.1 ករណីគ្មានកំហុស

នេះជារបាយការណ៍របស់គណៈកម្មាធិការត្រួតពិនិត្យរបស់សហគមន៍កសិកម្មអង្គររុងរឿង។

នៅថ្ងៃទី20-22 ខែកុម្ភៈ ឆ្នាំ2016 គណៈកម្មាធិការត្រួតពិនិត្យ បានត្រួតពិនិត្យ បញ្ជីគណនេយ្យ បញ្ជីសារពើភ័ណ្ឌ តារាងតុល្យការ របាយការណ៍លទ្ធផល(ចំណេញ ខាត) និងឯកសារសំខាន់ៗរបស់សហគមន៍កសិកម្ម ដោយគោរពតាមច្បាប់ស្តីពីសហគមន៍កសិកម្មក្នុង មាត្រា50 និងមាត្រា52ដែលតម្រូវឱ្យគណៈកម្មាធិការត្រួតពិនិត្យប្រើសិទ្ធិនិងកាតព្វកិច្ចត្រួតពិនិត្យបញ្ជីគណនេយ្យ របស់សហគមន៍កសិកម្ម ។

គណៈកម្មាធិការត្រួតពិនិត្យ បានរកឃើញថា គ្រប់ចំណុចក្នុងបញ្ជីគណនេយ្យ បញ្ជីសារពើភ័ណ្ឌ តារាងតុល្យការ របាយការណ៍លទ្ធផល(ចំណេញ ខាត) និងឯកសារសំខាន់ៗរបស់សហគមន៍កសិកម្មមានការរៀបចំត្រឹមត្រូវ។

**គណៈកម្មាធិការត្រួតពិនិត្យ**

**ហត្ថលេខា**

**ប្រធានគណៈកម្មាធិការត្រួតពិនិត្យ**

ឈ្មោះ៖ លោក កុម្ភៈ

ថ្ងៃទី22 ខែកុម្ភៈ ឆ្នាំ2015

### 10.2 ករណីមានកំហុស

នេះជារបាយការណ៍របស់គណៈកម្មាធិការត្រួតពិនិត្យរបស់សហគមន៍កសិកម្មអង្គររុងរឿង។

នៅថ្ងៃទី20-22 ខែកុម្ភៈ ឆ្នាំ2016 គណៈកម្មាធិការត្រួតពិនិត្យ បានត្រួតពិនិត្យ បញ្ជីគណនេយ្យ បញ្ជីសារពើភ័ណ្ឌ តារាងតុល្យការ របាយការណ៍លទ្ធផល(ចំណេញ ខាត) និងឯកសារសំខាន់ៗរបស់សហគមន៍កសិកម្ម ដោយគោរពតាមច្បាប់ស្តីពីសហគមន៍កសិកម្មក្នុង មាត្រា50 និងមាត្រា52ដែលតម្រូវឱ្យគណៈកម្មាធិការត្រួតពិនិត្យប្រើសិទ្ធនិងកាតព្វកិច្ចត្រួតពិនិត្យបញ្ជីគណនេយ្យ របស់សហគមន៍កសិកម្ម ។

គណៈកម្មាធិការត្រួតពិនិត្យ បានរកឃើញថា មានការក្លែងបន្លំឯកសារដូចបានរៀបរាប់ខាងក្រោម នៅក្នុងបញ្ជីគណនេយ្យ បញ្ជីសារពើភ័ណ្ឌ តារាងតុល្យការ របាយការណ៍លទ្ធផល(ចំណេញ ឬខាត) និង ឯកសារសំខាន់ៗរបស់សហគមន៍កសិកម្ម។ ឧទាហរណ៍៖ ក្នុងករណីដែលត្រួតពិនិត្យទៅឃើញមានកំហុសណាមួយ ដូចខាងក្រោម៖

- សាច់ប្រាក់ក្នុងដៃមិនគ្រប់តាមបញ្ជីសមតុល្យដែលនៅសល់
- ការចំណាយគ្មានវិក័យបត្រត្រឹមត្រូវ និងខុសនីតិវិធីចំណាយ
- ការចំណាយគ្មានការឯកភាពពីថ្នាក់ដឹកនាំ
- ការគណនាចំណូលចំណាយមិនត្រឹមត្រូវ
- ជាចំណាយផ្ទាល់ខ្លួន មិនមែនជាចំណាយរបស់សហគមន៍កសិកម្ម
- ការពិនិត្យរាប់ចំនួនសម្ភារៈរបស់សហគមន៍កសិកម្មមានបាត់បង់
- មិនមានបញ្ជីតាមដានសមាជិកឬមិនមែនសមាជិកខ្ចីប្រាក់ត្រឹមត្រូវ
- គ្មានបញ្ជីគ្រប់គ្រងផលិតផលរបស់សមាជិកត្រឹមត្រូវ
- រៀបចំកត់ត្រាក្នុងប្រព័ន្ធគណនេយ្យមិនបានត្រឹមត្រូវ

គណៈកម្មាធិការត្រួតពិនិត្យ នឹងមានគោលការណ៍មួយយោងតាមច្បាប់ខាងលើ សម្រេចឱ្យក្រុមប្រឹក្សាភិបាលត្រួតពិនិត្យឡើងវិញនិងកែតម្រូវនូវអ្វីដែលមិនមានភាពប្រក្រតីនិងប្រព្រឹត្តខុសខាងលើ។

**គណៈកម្មាធិការត្រួតពិនិត្យ**

**ហត្ថលេខា**

**ប្រធានគណៈកម្មាធិការត្រួតពិនិត្យៈ**

ឈ្មោះ៖ លោក កុម្ភៈ

ថ្ងៃទី22 ខែកុម្ភៈ ឆ្នាំ2016

## 11. **កំណត់ហេតុមហាសន្និបាតប្រចាំឆ្នាំរបស់សហគមន៍កសិកម្មដែលបានប្រព្រឹត្តទៅនៅថ្ងៃទី21 ខែមីនា ឆ្នាំ2016( ភ្ជាប់កំណត់ហេតុមហាសន្និបាត )**

ធ្វើនៅថ្ងៃទី22 ខែមីនា ឆ្នាំ2016

រៀបចំដោយ( អ្នកធ្វើរបាយការណ៍ )

ឈ្មោះ៖…………………………..

តួនាទី៖…………………………..

ហត្ថលេខា៖……………………..

បានឃើញនិងឯកភាព

ប្រធានសហគមន៍កសិកម្ម៖ លោក មករា

ហត្ថលេខា៖.....................................

## កំណត់ហេតុមហាសន្និបាតប្រចាំឆ្នាំរបស់សហគមន៍កសិកម្មអង្គររុងរឿង

### 1.សេចក្ដីផ្ដើម

ថ្ងៃទី21 ខែមីនា ឆ្នាំ2016 នៅវេលាម៉ោង 8:30-16:00 នៅសហគមន៍កសិកម្មអង្គររុងរឿងបានរៀបចំមហាសន្និបាតប្រចាំឆ្នាំក្រោមការដឹកនាំរបស់លោក មករា ដែលជាប្រធានសហគមន៍កសិកម្ម និងលោក ដារ៉ា ដែលជាអ្នកកត់កំណត់ហេតុមហាសន្និបាត។ សមាជិកដែលបានចូលរួមមានចំនួន 95នាក់ ក្នុងចំណោមសមាជិក១២០នាក់ (ជូនភ្ជាប់បញ្ជីវត្តមាន) ។

### 2.របៀបវារៈ និង លទ្ធផលនៃសេចក្ដីសម្រេច

1. របាយការណ៍មុខជំនួញរបស់សហគមន៍កសិកម្មសម្រាប់ឆ្នាំ2015
   - សេចក្ដីសម្រេច៖ របាយការណ៍នេះបានឯកភាពដោយសមាជិកសហគមន៍កសិកម្មទាំងអស់
2. របាយការណ៍ហិរញ្ញវត្ថុរបស់សហគមន៍កសិកម្មសម្រាប់ឆ្នាំ2015
   - សេចក្ដីសម្រេច៖ របាយការណ៍ហិរញ្ញវត្ថុនេះត្រូវបានឯកភាពដោយសមាជិកទាំងអស់
3. ការបែងចែកប្រាក់ចំណេញរបស់សហគមន៍កសិកម្មដល់សមាជិកសម្រាប់ឆ្នាំ2015
   - សេចក្ដីសម្រេច៖ ត្រូវបានអនុម័តបែងចែកឱ្យសមាជិកទាំងអស់
4. ការអនុម័តសមាជិកថ្មីនិងសមាជិកសុំឈប់សម្រាប់ឆ្នាំ2015
   - សេចក្ដីសម្រេច៖ ត្រូវបានអនុម័តដោយសមាជិកទាំងអស់
5. ការអនុម័តនូវផែនការមុខជំនួញសម្រាប់ឆ្នាំ2016
   - សេចក្ដីសម្រេច៖ ត្រូវបានអនុម័តដោយសមាជិកទាំងអស់
6. ការកែប្រែលក្ខន្តិកៈ ការកែប្រែបទបញ្ជាផ្ទៃក្នុង
   - សេចក្ដីសម្រេច៖ បទបញ្ជាផ្ទៃក្នុងត្រូវបានកែប្រែ និងអនុម័តដោយសមាជិកទាំងអស់

ថ្ងៃទី22 ខែមីនា ឆ្នាំ2016

អ្នកធ្វើកំណត់ហេតុ៖ លោក ដារ៉ា

ហត្ថលេខា៖ ……………………

បានឃើញ និងឯកភាពដោយ

ប្រធានសហគមន៍កសិកម្ម៖ លោក មករា

ហត្ថលេខា៖ …………………………..

Annual Report Sample

Printed in February 2016

Published by Department of Agricultural Cooperative Promotion of GDA (MAFF)

The Project for Establishing Business Oriented Agricultural Cooperative Models (BPAC)

Address: #54B/49F.St395-656,Sangkat Toeuk Laak 3 Khan Tuol Kok, Phnom penh ,Cambodia,

Phone: (023) 883 427, Fax : 023) 883 427

© The Project for Establishing Business-Oriented Agricultural Cooperative Models

**Supported by Japan International Cooperation Agency (JICA)**